ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង : ៩៥/១១- សាញនីង ( ប៊ូមីង )**

**កាលបរិច្ឆេទនៃសេចក្តីសម្រេច : ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១១**

# សេចក្តីសម្រេចអាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: **យូ សូនទី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: **លីវ សុវណ្ណា**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

១- ភាគីនិយោជក

ឈ្មោះ : **ក្រុមហ៊ុន ប៊ូមីង ថេកស្តាយ ខបភើរេសិន (សាញនីង ថេកស្តាយ ខប)**

អាសយដ្ឋាន : ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០៨៩ ៧៥៣ ៤០៦ ទូរសារ : គ្មាន

តំណាងភាគីនិយោជកចូលរួមសវនាការលើកទី១ និងទី២:

- លោក ឆេង ប្រសើរ ប្រធានរដ្ឋបាល

២- ភាគីកម្មករនិយោជិត

ឈ្មោះ : - **សហព័ន្ធសហជីពយុវជនខ្មែរ**

- **សហជីពយុវជនខ្មែរក្រុមហ៊ុន ប៊ូមីង ថិចស្តាយខបភើរេសិន**

អាសយដ្ឋាន : ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៩៤០ ៥៤៨ ទូរសារ : គ្មាន

តំណាងកម្មករនិយោជិតចូលរួមសវនាការលើកទី១:

១- លោក សៀ សន មន្ត្រីសហព័ន្ធសហជីពយុវជនខ្មែរ

២- លោក វៀត សោភា ប្រធានសហជីពយុវជនខ្មែរប្រចាំក្រុមហ៊ុន

៣- លោកស្រី ឌុប ឌឿន អនុប្រធានសហជីព

៤- លោកស្រី អ៊ុក ស្រីល័ក្ខ លេខាធិការសហជីព

តំណាងកម្មករនិយោជិតចូលរួមសវនាការលើកទី២:

១- លោក ម៉ៃ វឌ្ឍនា អនុប្រធានសហព័ន្ធសហជីពយុវជនខ្មែរ

២- លោក សៀ សន មន្ត្រីសហព័ន្ធសហជីពយុវជនខ្មែរ

៣- លោក វៀត សោភា ប្រធានសហជីពយុវជនខ្មែរប្រចាំក្រុមហ៊ុន

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- សុំឱ្យក្រុមហ៊ុនរៀបចំថ្នាំពេទ្យឱ្យបានគ្រប់គ្រាន់ និងគ្រូពេទ្យប្រចាំការរៀងរាល់ម៉ោងធ្វើការ ។

២- សុំកុំឱ្យក្រុមហ៊ុនមានការរើសអើង ឬបញ្ឈប់ចំពោះស្ត្រីមានផ្ទៃពោះ ។

៣- ចំពោះកម្មករនិយោជិតដែលមានជំងឺ ហើយមានលិខិតបញ្ជាក់ពីគ្រូពេទ្យត្រឹមត្រូវ សុំឱ្យក្រុមហ៊ុនរក្សាប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗនៅដដែល ។

៤- ក្នុងករណីកម្មករនិយោជិតមកធ្វើការយឺតរយៈពេល ៣០ នាទី ដោយបញ្ហាឡាន ឬម៉ូតូខូច សុំឱ្យក្រុមហ៊ុនរក្សាប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ៧ ដុល្លារ ។

៥- សុំឱ្យក្រុមហ៊ុនបើកប្រាក់ឈ្នួលរបស់កម្មករនិយោជិតឱ្យបានទៀងទាត់មិនលើសពីថ្ងៃទី១០ រៀងរាល់ខែ ។

៦- សុំឱ្យក្រុមហ៊ុនរៀបចំឱ្យមានរោងបាយ ព្រមទាំងតុអង្គុយ និងមានទូដាក់សំភារៈបាយ ។

៧- នៅពេលកម្មករនិយោជិតសុំច្បាប់ឈប់សម្រាកពិសេស សុំឱ្យក្រុមហ៊ុនអនុញ្ញាតិមានភាពងាយស្រួល ព្រមទាំងរក្សាអត្ថប្រយោជន៍ផ្សេងៗទៅតាមច្បាប់ស្តីពីការងារ ។

៨- នៅពេលកម្មករនិយោជិតធ្វើការបន្ថែមសុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់ថ្លៃបាយចំនួន ១០០០ រៀល ចាប់ពីម៉ោង ១៨:០០ ឡើងទៅ ។

៩- សុំឱ្យក្រុមហ៊ុនអនុវត្តការបន្ថែមម៉ោងផ្អែកទៅលើគោលការណ៍ស្ម័គ្រចិត្តរបស់កម្មករនិយោជិត ។

១០- សុំឱ្យក្រុមហ៊ុនធ្វើកិច្ចសន្យាការងារដែលមានថិរវេលាកំណត់ ០៦ ខែម្តង ។

THE ARBITRATION COUNCIL

១១- នៅពេលកម្មករនិយោជិតធ្វើការថ្ងៃអាទិត្យ សុំឱ្យក្រុមហ៊ុនផ្តល់បាយមួយពេល ឬប្រាក់ថ្លៃបាយចំនួន ៣០០០ រៀល ។

១២- ក្នុងករណីកម្មករនិយោជិតដាក់លិខិតលាឈប់ពីការងារមុនថ្ងៃផុតកំណត់នៃកិច្ចសន្យាការងារដោយជូនដំណឹងមុន សុំឱ្យក្រុមហ៊ុនទូទាត់ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗជូនកម្មករនិយោជិត ។

១៣- សុំឱ្យក្រុមហ៊ុនណែនាំប្រធានក្រុមមិនឱ្យប្រើពាក្យសំដី ឬអាកប្បកិរិយាសមរម្យមកលើកម្មករនិយោជិត ។

១៤- សុំឱ្យក្រុមហ៊ុនកាត់ប្រាក់ឈ្នួលរបស់កម្មករនយោជិតក្នុងម្នាក់ៗចំនួន ១០០០ រៀល ដើម្បីបង់ភាគទានជូនសហជីព ក្នុងករណីចូលជាសមាជិកសហជីពយុវជនខ្មែរ ។

១៥- សុំឱ្យក្រុមហ៊ុនបើកប្រាក់ថ្លៃឡានដែលក្រុមហ៊ុនផ្តល់ជូនកម្មករនិយោជិតចំនួន ៦ ដុល្លារ ក្នុងមួយខែម្តង ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ)( មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ ( អាណត្តិទី៥) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ ( ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ៨៤២ ក.ប/អក/វ.ក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១១។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :**

- លើកទី១ : ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០១១ ( វេលាម៉ោង ០៨:០០ នាទី ព្រឹក ) ។
- លើកទី១ : ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១១ ( វេលាម៉ោង ១៤:៣០ នាទី រសៀល ) ។

**បញ្ហានៃនីតិវិធីៈ**

នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១១ នាយកដ្ឋានវិវាទការងារបានទទួលពាក្យបណ្តឹងរបស់សហព័ន្ធសហជីពយុវជនខ្មែរ ប្រចាំរោងចក្រ ស្តីពីការទាមទារឱ្យក្រុមហ៊ុនអនុវត្តច្បាប់ស្តីពីការងារឱ្យបានត្រឹមត្រូវ។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារ បានចាត់តាំងមន្ត្រីជំនាញឱ្យធ្វើការដោះស្រាយវិវាទការងាររួមចំនួន ១៥ ចំណុចនេះ នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១១ ដោយពុំទទួលបានលទ្ធផលសះជានឹងគ្នាទេ។ ចំណុចវិវាទមិនសះទាំង ១៥ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១១ តាមរបាយការណ៍ដោះស្រាយវិវាទការងាររួមមិនសះជាលេខ ៨៤២/១០ កប/អក/វក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១១។

បន្ទាប់ពីបានទទួលសំណុំរឿងនេះរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិត មកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ១៥ ចំណុចនេះ នៅថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១១ វេលាម៉ោង ៨:០០ នាទី ព្រឹក និងថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១១ វេលាម៉ោង ១៤:៣០ នាទី រសៀល។

ភាគីទាំងពីរមានវត្តមាននៅថ្ងៃសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកនូវព័ត៌មានផ្សេងៗ ដែលទាក់ទងទៅនឹងវិវាទនេះ និងបានធ្វើការផ្សះផ្សាលើចំណុចមិនសះជាទាំង ១៥ ចំណុចនេះ បន្ថែមទៀត ដោយភាគីកម្មករនិយោជិត និងភាគីនិយោជកបានបញ្ជាក់ថា ក្នុងចំណោមចំណុចវិវាទ ១៥ ចំណុចនេះ មានចំណុចវិវាទី១ ទី២ ទី៣ ទី៤ ទី៥ ទី៧ ទី៨ ទី៩ ទី១០ ទី១២ ទី១៣ ទី១៤ និងទី១៥ និយោជក និងកម្មករនិយោជិតបានធ្វើការដោះស្រាយឈានដល់ការព្រមព្រៀងគ្នារួចហើយ គឺនៅសល់តែចំណុចវិវាទទី៦ និងចំណុចវិវាទី១១ ប៉ុណ្ណោះ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសួររកនូវព័ត៌មានផ្សេងៗ ដែលទាក់ទងនឹងវិវាទ ២ ចំណុច ដែលនៅសល់នេះ បន្ថែមទៀត ហើយក៏បានធ្វើការផ្សះផ្សាបន្ថែមផងដែរនោះ ភាគីទាំងពីរបានឈានដល់ការព្រមព្រៀងចំណុចវិវាទទី៦ ផងដែរ។ ប៉ុន្តែ មិនយល់ព្រមចុះហត្ថលេខាទេ គឺស្នើសុំឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលសរសេរនៅក្នុងសេចក្តីបង្គាប់នេះ។ ចំណុចព្រមព្រៀងចំណុចវិវាទទី៦ : ក្រុមហ៊ុនឯកភាពរៀបចំឱ្យមានរោងបាយព្រមទាំងមានតុអង្គុយ នៅក្នុងខែ កញ្ញា ឆ្នាំ ២០១១។

ដោយសារភាគីទាំងពីរជាហត្ថលេខីនៃអនុស្សរណៈនៃការយោគយល់គ្នាចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈក្នុងឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ ដូចនេះក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងបែងចែកសេចក្តីសម្រេចនៃចំណុចវិវាទជាពីរ គឺចំណុចវិវាទអំពីសិទ្ធិ និងចំណុចវិវាទអំពីប្រយោជន៍។ ភាគីទាំងពីរមិនមានសិទ្ធិប្តឹងជំទាស់លើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើចំណុចវិវាទអំពីសិទ្ធិនោះទេ ព្រោះភាគីទាំងពីរបានព្រមព្រៀងគ្នា ឱ្យសេចក្តីសម្រេចនេះ ជាសេចក្តីសម្រេចដែលជាប់

THE ARBITRATION COUNCIL

កាតព្វកិច្ចតាមរយៈអនុស្សរណៈនៃការយោគយល់គ្នា ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០ រួចហើយ។ ប៉ុន្តែ ភាគីអាចប្តឹងជំទាស់ទៅលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើវិវាទអំពីប្រយោជន៍ ប្រសិនបើភាគីជ្រើសរើសយកសេចក្តីសម្រេចមិនជាប់កាតព្វកិច្ចចំពោះវិវាទអំពីប្រយោជន៍។

ការប្តឹងជំទាស់របស់ភាគីទៅនឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល លើចំណុចវិវាទអំពីប្រយោជន៍ នឹងមិនបណ្តាលឱ្យប៉ះពាល់ទៅដល់កាតព្វកិច្ចក្នុងការអនុវត្តសេចក្តីសម្រេច ដែលជាវិវាទអំពីសិទ្ធិទេ ដោយអនុលោមតាមស្មារតីនៃអនុស្សារណៈនៃការយោគយល់គ្នាខាងលើនោះ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម:

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

**ក- ឯកសារបានទទួលពីភាគីនិយោជក :**

១- លិខិតប្រគល់សិទ្ធិរបស់ប្រធានក្រុមហ៊ុន សាញនីង ជូនលោក ឆេង ប្រសើរ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១១ ។

២- វិញ្ញាបនប័ត្របញ្ជាក់ការចុះបញ្ជីក្នុងប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ក្រុមហ៊ុន ប៊ូមីង លេខ ០៨៣៩ ពណ.បអព ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១១ ។

៣- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ប៊ូមីង ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១១ ។

៤- កិច្ចព្រមព្រៀងស្តីពីការសម្រុះសម្រួលករណីវិវាទការងាររវាងកម្មករនិយោជិត និងក្រុមហ៊ុន ឆាងឡុង ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១១ ។

៥- កិច្ចព្រមព្រៀងស្តីពីការសម្រុះសម្រួលករណីវិវាទការងាររវាងកម្មករនិយោជិត និងក្រុមហ៊ុន ប៊ូមីង (ឆាំងឡុង) ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១១ ។

៦- កិច្ចព្រមព្រៀងស្តីពីការសម្រុះសម្រួលករណីវិវាទការងាររវាងកម្មករនិយោជិត និងក្រុមហ៊ុន ឆាងឡុង (សាញនីង) ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១១ ។

៧- លក្ខន្តិកៈ និងអនុស្សរណៈ ក្រុមហ៊ុន ប៊ូមីង ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១០ ។

៨- លិខិតរបស់ក្រុមហ៊ុន សាញនីង ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១១ គោរពជូនលោកប្រធានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីការសុំពន្យាពេលសវនាការនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១១ ។

៩- វិញ្ញាបនប័ត្របញ្ជាក់ការចុះបញ្ជីក្នុងប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ក្រុមហ៊ុន សាញនីង លេខ ៣២៤៨ ពណ.បអព ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១១ ។

១០- ប័ណ្ណប៉ាតង់ឆ្នាំ២០១១ ក្រុមហ៊ុន សាញនីង ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១១ ។

១១- ឯកសារជាភាសាបរទេស ។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :**

១- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពយុវជនខ្មែរក្រុមហ៊ុន ប៊្លូមីង ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១១។

២- បង្កាន់ដៃសុំទទួលស្គាល់ថ្នាក់ដឹកនាំថ្មី ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១១ ។

៣- លិខិតរបស់សហព័ន្ធសហជីពយុវជនខ្មែរ លេខ ១៦០ សសយខ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១១ គោរពជូន លោកនាយកក្រុមហ៊ុន ឆាង ឡុង ស្តីពីការជូនដំណឹងពីការបោះឆ្នោតផ្លាស់ប្តូរថ្នាក់ដឹកនាំសហជីពយុវជនខ្មែរប្រចាំក្រុមហ៊ុន ឆាង ឡុង ។

៤- លិខិតរបស់សហព័ន្ធសហជីពយុវជនខ្មែរ លេខ ១៦០ សសយខ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១១ គោរពជូន លោកនាយកក្រុមហ៊ុន សាញនីង ស្តីពីការជូនដំណឹងពីការបោះឆ្នោតផ្លាស់ប្តូរថ្នាក់ដឹកនាំសហជីពយុវជនខ្មែរប្រចាំក្រុមហ៊ុន សាញនីង ។

៥- កាតសំគាល់កម្មការិនីឈ្មោះ សួន សុខយ៉េត នៃក្រុមហ៊ុន សាញនីង ។

៦- កំណត់ហេតុសាកសួរព័ត៌មានពីតំណាងកម្មករនិយោជិតនៃក្រុមហ៊ុន ប៊្លូមីង ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១១ ។

៧- លិខិតរបស់ឈ្មោះ វៀត សោភា ជាប្រធានសហជីពយុវជនខ្មែរ គោរពជូន ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសុំប្តឹងជំទាស់ និងឯកសាររបស់ក្រុមហ៊ុន ប៊្លូមីង ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១១។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ប៊្លូមីង លេខ ៤៨២ ក.ប/អក/វ.ក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១១។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ប៊្លូមីង ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១១។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលើកទី១ លេខ ៥៤៦ កប/អក/វក/លកអ. ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១១។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលើកទី១ លេខ ៥៤៥ កប/អក/វក/លកអ. ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១១។

៣- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលើកទី២ លេខ ៥៧៤ កប/អក/វក/លកអ. ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ២០១១។

៤- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលើកទី២ លេខ ៥៧៥ កប/អក/វក/លកអ. ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១១។

៥- ការព្រមព្រៀងយកសេចក្ដីបង្គាប់ជាប់កាតព្វកិច្ចលើចំណុចវិវាទអំពីសិទ្ធិ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ ២០១១។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្ដាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញថា :**

- ក្រុមហ៊ុន សាញនីង (ប៊្លូ មីង) ចាប់ដំណើរការនៅឆ្នាំ ២០១១ ដោយមានជួលកម្មករនិយោជិតចំនួន ៣៣០ នាក់។
- សហជីពយុវជនខ្មែរប្រចាំក្រុមហ៊ុន ទទួលបានវិញ្ញាប័ត្រចុះបញ្ជិកា នៅថ្ងៃថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១១។

**ចំណុចវិវាទទី១១ : កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្ដល់បាយមួយពេល ឬប្រាក់ថ្លៃបាយចំនួន ៣០០០ រៀល នៅពេលកម្មករនិយោជិតធ្វើការ នៅថ្ងៃអាទិត្យ**

- ក្រុមហ៊ុនបានអនុវត្តម៉ោងការងារ ពីថ្ងៃចន្ទ រហូតដល់ថ្ងៃសៅរ៍ ដោយចាប់ផ្ដើមចូលធ្វើការនៅម៉ោង ៧:០០ ព្រឹក និងចប់ការងារនៅម៉ោង ៤:០០ រសៀល ពោលគឺ ធ្វើការចំនួន ៨ ម៉ោង ក្នុងមួយថ្ងៃ ហើយថ្ងៃអាទិត្យជាថ្ងៃឈប់សម្រាកប្រចាំសប្ដាហ៍។
- នៅពេលក្រុមហ៊ុនមានការងារឱ្យកម្មករនិយោជិតធ្វើនៅថ្ងៃអាទិត្យ ក្រុមហ៊ុនអនុវត្តដោយផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត គឺចូលធ្វើការនៅម៉ោង ៧:០០ ព្រឹក និងចប់ការងារនៅម៉ោង ៤:០០ រសៀល ពោលគឺធ្វើការចំនួន ៨ ម៉ោង ក្នុងមួយថ្ងៃ ដូចថ្ងៃធ្វើការធម្មតាដែរ ដោយក្រុមហ៊ុនផ្ដល់ប្រាក់ឈ្នួលចំនួន ២០០ ភាគរយ។ ប៉ុន្តែ ក្រុមហ៊ុនមិនបានផ្ដល់បាយមួយពេល ឬប្រាក់ថ្លៃបាយសម្រាប់ធ្វើការនៅថ្ងៃអាទិត្យនោះទេ។
- ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្ដល់បាយមួយពេល ឬប្រាក់ថ្លៃបាយ ចំនួន ៣០០០ រៀល ដោយលើកមូលហេតុថា កម្មករនិយោជិតស្ម័គ្រចិត្តធ្វើការនៅថ្ងៃអាទិត្យ ជាការងារបន្ថែមម៉ោង ត្រូវទទួលបានបាយមួយពេល ឬប្រាក់ប្រាក់ថ្លៃបាយនេះ។

THE ARBITRATION COUNCIL

- ភាគីកម្មករនិយោជិតបានបញ្ជាក់ថា មូលហេតុដែលពួកគាត់ទាមទារឱ្យក្រុមហ៊ុនផ្តល់បាយមួយពេល ឬប្រាក់ថ្លៃបាយចំនួន ៣០០០ រៀល ពីព្រោះទំនិញទីផ្សារ និងម្ហូបអាហារឡើងថ្លៃ ហើយបាយមួយកញ្ចប់តម្លៃពី ២៥០០ រៀល ទៅ ៣០០០ រៀល។ម្យ៉ាងទៀត កម្មករនិយោជិតមិនបានឈប់សម្រាកទេ ដោយស្ម័គ្រចិត្តធ្វើការជូនក្រុមហ៊ុន។ ហេតុនេះ ពួកគាត់សុំឱ្យក្រុមហ៊ុនផ្តល់ ៣០០០ រៀល ឬ បាយមួយពេលនេះ។
- ភាគីភាគីនិយោជកបានបញ្ជាក់ថា និយោជកទទួលស្គាល់ថា ការធ្វើការថ្ងៃអាទិត្យជាការងារបន្ថែមម៉ោង ប៉ុន្តែនិយោជក បានផ្តល់ប្រាក់ឈ្នួលធ្វើការថ្ងៃអាទិត្យ តាមអាត្រាតម្លើង ២០០ ភាគរយ រួចហើយ។ ហេតុនេះក្រុមហ៊ុនមិនអាចផ្តល់ជូនតាមការទាមទាររបស់កម្មករនិយោជិតបានទេ។ បើច្បាប់ស្តីពីការងារតម្រូវឱ្យក្រុមហ៊ុនផ្តល់ជូនក្រុមហ៊ុននឹងអនុវត្តតាម។

**ហេតុផលនៃសេចក្តីសម្រេច:**

មុននឹងពិចារណាលើចំណុចទាមទារនៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាលើភាពជាតំណាងរបស់ភាគីនៅក្នុងវិវាទនេះជាមុនសិន។

នៅថ្ងៃសវនាការ ភាគីនិយោជកដែលតំណាងដោយប្រធានរដ្ឋបាលមានវត្តមានតាមការអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ហើយគាត់ទទួលបានលិខិតផ្ទេរសិទ្ធិពីប្រធានក្រុមហ៊ុន ឈ្មោះ Liang Yan Ke ដែលលោកធ្វើការផ្ទេរសិទ្ធិជំនួសលោកនាយកក្រុមហ៊ុន។ ភាគីកម្មករនិយោជិតបដិសេធមិនទទួលស្គាល់សមាសភាពរបស់ប្រធានរដ្ឋបាល ដែលជាតំណាងរបស់ក្រុមហ៊ុនទេ ដោយសារ នៅក្នុងបណ្ណ័ប៉ាតង់របស់ក្រុមហ៊ុន ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១១ គឺបានបញ្ជាក់យ៉ាងច្បាស់ថា អ្នកគ្រប់គ្រងក្រុមហ៊ុន គឺលោក Chung Yang Yu មិនមែនជា Liang Yan Ke ទេ។ ភាគីកម្មករនិយោជិតបញ្ជាក់ថា អ្នកដែលមានសិទ្ធិផ្ទេរសិទ្ធិឱ្យប្រធានរដ្ឋបាល គឺមានតែ Chung Yang Yu ប៉ុណ្ណោះ។

ប្រការ ១៩ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា *"ភាគីវិវាទអាចមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាលដោយផ្ទាល់ខ្លួន ឬដោយមានអ្នកអម...ឬដោយបុគ្គលផ្សេងទៀតដែលទទួលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីភាគីនោះ"*។

យោងតាមប្រការ១៩ នៃប្រកាសលេខ ៩៩/០៤ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ពាក្យថា **"ទទួលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សរ"** បានន័យថា ភាគីវិវាទអាចឱ្យបុគ្គលផ្សេងតំណាងឱ្យខ្លួន ក្នុងការដោះស្រាយវិវាទការងារនៅចំពោះមុខក្រុមអាជ្ញាកណ្តាលបាន លុះត្រាបុគ្គលនោះ ទទួលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សរ ដើម្បីមកធ្វើជាតំណាងរបស់ភាគីវិវាទ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ *១៦១/០៩-ព្រែកត្រែង និងលេខ ៤៣/១០-ម៉ឺង ដឿន*)។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា នៅក្នុងលិខិតផ្ទេរសិទ្ធិនោះ គឺមានឈ្មោះក្រុមហ៊ុននៅលើក្បាលលិខិត និង ត្រារបស់ក្រុមហ៊ុន ហើយមានឈ្មោះ Liang Yan Ke ជាប្រធានក្រុមហ៊ុន ហើយដែលបញ្ជាក់នូវពាក្យ ជ.នាយក មានន័យថា ជួសនាយកក្រុមហ៊ុន។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ជាទូទៅលិខិតផ្លូវការដែលចាត់ទុកថាមានលក្ខណៈគតិយុត្តិត្រឹមត្រូវនោះ គឺលិខិតដែលមានក្បាលលិខិតបញ្ជាក់ ពីឈ្មោះរបស់ស្ថាប័ន អង្គការ ឬ ក្រុមហ៊ុន និង មានត្រាដើម្បីបញ្ជាក់។ ជាក់ស្តែង ដូចជាករណីវិញ្ញាប័ត្រចុះបញ្ជិការបស់សហជីពយុវជនខ្មែរក្រុមហ៊ុន ប៊្ញូមីង ឱចថាយ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១១ គឺមិនមែនរដ្ឋមន្ត្រីក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ចុះហត្ថលេខាទេ គឺអនុរដ្ឋលេខាធិការ ជាអ្នកចុះហត្ថលេខាជួសរដ្ឋមន្ត្រី ដោយមានបោះត្រារបស់ក្រសួង។ ករណីមួយទៀត ដូចជាបណ្ណ័ប៉ាតង់របស់ក្រុមហ៊ុន គឺមានតែប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ជាអ្នកចុះហត្ថលេខា ដោយមានបោះត្រារបស់អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ លើសពីនេះទៀត វចនាសម្ព័ន្ធនៅតាមស្ថាប័នរដ្ឋ អង្គការ ឬ ក្រុមហ៊ុននានា នៅពេលដែលថ្នាក់ដឹកនាំធំ ជាប់រវល់នៅក្រៅស្រុក គឺអ្នកគ្រប់គ្រងផ្សេងទៀតត្រូវទទួលភារកិច្ចគ្រប់គ្រងបន្តជាបណ្តោះអាសន្ន។

ដូចនេះ បើទោះបីជាលោក Liang Yan Ke មិនមានឈ្មោះនៅក្នុងបណ្ណ័ប៉ាតង់នោះក៏ដោយ ក៏ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា លោក Liang Yan Ke ធ្វើការងារជួសនាមនាយកក្រុមហ៊ុន ដែលមានបញ្ជាក់នៅក្នុងលិខិតផ្ទេរសិទ្ធិ។

សរុបមក យោងតាមប្រការ ១៩ នៃប្រកាសលេខ ០៩៩ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ប្រធានរដ្ឋបាលមានសិទ្ធិតំណាងឱ្យក្រុមហ៊ុនក្នុងការដោះស្រាយវិវាទនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ពីព្រោះគាត់ទទួលបានលិខិតអនុញ្ញាតជាលាយលក្ខណ៍អក្សរពីប្រធានក្រុមហ៊ុន។

**ចំណុចវិវាទទី១១ : កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្តល់បាយមួយពេល ឬប្រាក់ថ្លៃបាយចំនួន ៣០០០ រៀល នៅពេលកម្មករនិយោជិតធ្វើការ នៅថ្ងៃអាទិត្យ**

មុននឹងពិចារណាចំណុចវិវាទទាំង១១ នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើចំណុចវិវាទនេះជាវិវាទអំពីសិទ្ធិដែរ ឬទេ?

ក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា *"វិវាទអំពីសិទ្ធិ គឺជាវិវាទទាក់ទងនឹងសិទ្ធិដែលមានចែងក្នុងច្បាប់ កិច្ចព្រមព្រៀង ឬអនុសញ្ញាឬមណាមួយចែងពីការទាមទារនោះ"*។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ *០៥/១១-អ៊ឹម វ៉េ (សាខាទី១) ហេតុផលចំណុចវិវាទទី១ និង៥, លេខ ១៣/១១-ហ្គូល ការីម៉ុច ហេតុផលចំណុចវិវាទទី១ និង២ និងលេខ ១៤/១១-ជី អេច ជី ហេតុផលចំណុចវិវាទទី៤*)។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងខាងលើដែរ។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ចំណុចវិវាទទី១១នេះ គឺជាវិវាទអំពីសិទ្ធិ ព្រោះវិវាទអំពីប្រាក់ថ្លៃបាយ ឬបាយមួយពេលដោយមិនគិតថ្លៃនៅថ្ងៃអាទិត្យ ពាក់ពន្ធ័នឹងសិទ្ធិដែលមានចែងក្នុងសេចក្តីជូនដំណឹងលេខ ០៤១/១១។ ចំណែកវិវាទទាក់ទងនឹងប្រាក់ថ្លៃបាយចំនួន ៣០០០ រៀល សម្រាប់ការងារថ្ងៃអាទិត្យ គឺជាវិវាទអំពីផលប្រយោជន៍ ព្រោះវិវាទនេះ លើសពីអត្ថប្រយោជន៍ដែលចែងក្នុងសេចក្តីជូនដំណឹងលេខ ០៤១/១១។

ក្នុងករណីនេះ ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្តល់បាយមួយពេល ឬ ប្រាក់ថ្លៃបាយចំនួន ៣០០០ រៀល ដោយលើកមូលហេតុថា កម្មករនិយោជិតស្ម័គ្រចិត្តធ្វើការនៅថ្ងៃអាទិត្យជាការងារបន្ថែមម៉ោង។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើនិយោជកមានកាតព្វកិច្ចផ្តល់បាយមួយពេល ឬប្រាក់ចំនួន ៣០០០ រៀល ដល់កម្មករនិយោជិតដែលស្ម័គ្រចិត្តមកធ្វើការនៅថ្ងៃអាទិត្យ ដែរ ឬទេ?

មាត្រា ១៣៧ នៃច្បាប់ស្តីពីការងារ ចែងថា "*គ្រឹះស្ថានប្រភេទណាក៏ដោយ ទោះបីគ្រឹះស្ថាននោះមានលក្ខណៈជាការសិក្សាវិជ្ជាជីវៈ ឬជាកិច្ចកុសល ព្រមទាំងនៅក្នុងវិជ្ជាជីវៈសេរីក៏ដោយ ថិរវេលាធ្វើការពេញលេញនៃកម្មករនិយោជិតទាំងពីរភេទ មិនត្រូវឱ្យលើសពីប្រាំបីម៉ោងក្នុងមួយថ្ងៃ ឬសែសិបប្រាំបីម៉ោងម៉ោង ក្នុងមួយអាទិត្យឡើយ។*"

នៅក្នុងសេចក្តីបង្គាប់លេខ ១១៤/០៨-វ៉ាយ ធិច ចំណុចវិវាទទី៥ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថា "*ថិរវេលាធ្វើការធម្មតារបស់កម្មករនិយោជិត ៨ ម៉ោងក្នុងមួយថ្ងៃ ឬ ៤៨ ម៉ោងក្នុងមួយសប្តាហ៍ ពីថ្ងៃច័ន្ទ ដល់ថ្ងៃសៅរ៍។ ក្រៅពីថ្ងៃដែលកម្មករនិយោជិតធ្វើការលើសពីម៉ោងធម្មតានេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ជាការងារបន្ថែមម៉ោង*" ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនដែរ។ តាមអត្ថន័យនៃមាត្រា ១៣៧ នៃច្បាប់ស្តីពីការងារ និងយុត្តិសាស្ត្ររបស់អាជ្ញាកណ្តាលខាងលើនេះ មានន័យថា ថិរវេលាធ្វើការធម្មតារបស់កម្មករនិយោជិតមិនត្រូវលើស ៨ ម៉ោង ក្នុងមួយថ្ងៃ ឬ ៤៨ ម៉ោង ក្នុងមួយសប្តាហ៍ ឡើយ។ ក្នុងករណីនេះ ក្រុមហ៊ុនបានឱ្យកម្មករនិយោជិតធ្វើការពីថ្ងៃចន្ទ ដល់ថ្ងៃសៅរ៍ មួយថ្ងៃ ៨ ម៉ោង គឺស្មើនឹង ៤៨ ម៉ោង ក្នុងមួយសប្តាហ៍ ហើយថ្ងៃអាទិត្យជាថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍មិនមែនជាថ្ងៃធ្វើការធម្មតារបស់ក្រុមហ៊ុនទេ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា បើសិនជាកម្មករស្ម័គ្រចិត្តធ្វើការនៅថ្ងៃអាទិត្យ គឺកម្មករនិយោជិតធ្វើការលើសពីម៉ោងធ្វើការធម្មតា។ ហេតុនេះ កម្មករនិយោជិតដែលស្ម័គ្រចិត្តធ្វើការនៅថ្ងៃអាទិត្យ ដែលលើសពីថ្ងៃ និងម៉ោងធ្វើការធម្មតា ជាការងារបន្ថែមម៉ោង។

យោងតាមចំណុចទី២ នៃសេចក្តីជូនដំណឹងលេខ ០៤១ សកបយ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១១ ចែងថា *"កម្មករនិយោជិត ដែលស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោងតាមសំណូមពររបស់និយោជក ត្រូវទទួលបានប្រាក់ថ្លៃបាយ ចំនួន ២០០០ (ពីរពាន់) រៀល ក្នុងមួយថ្ងៃ ឬទទួលបានការផ្តល់ជូនបាយមួយពេល ដោយឥតគិតថ្លៃ"*។

ដោយសារការងារនៅថ្ងៃអាទិត្យ ជាការងារបន្ថែមម៉ោង ដូចនេះតាមខ្លឹមសារនៃចំណុចទី២ នៃសេចក្តីជូនដំណឹងខាងលើនេះ កម្មករនិយោជិតដែលស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោងតាមសំណូមពររបស់និយោជកត្រូវទទួលបានប្រាក់ថ្លៃបាយចំនួន ២០០០ (ពីរពាន់) រៀល ក្នុងមួយថ្ងៃ ឬទទួលបានការផ្តល់ជូនថ្លៃបាយមួយពេលដោយឥតគិតថ្លៃ ដោយមិនកំណត់ថា ធ្វើការថែមម៉ោងប៉ុន្មានម៉ោងទេ។

តាមអង្គហេតុ និយោជកមិនដែលផ្តល់ជូននូវប្រាក់ថ្លៃបាយនេះដល់កម្មករនិយោជិតទេ។ ហេតុនេះ និយោជកត្រូវផ្តល់ប្រាក់ថ្លៃបាយ ចំនួន ២០០០ (ពីរពាន់) រៀល ក្នុងមួយថ្ងៃ ឬ ផ្តល់ជូនបាយមួយពេល ដោយឥតគិតថ្លៃ តាមសេចក្តីជូន ដំណឹង លេខ ០៤១ សកបយ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១១។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចឱ្យនិយោជកផ្តល់ប្រាក់ថ្លៃបាយ ចំនួន ២០០០ (ពីរពាន់) រៀល ក្នុងមួយថ្ងៃ ឬផ្តល់ជូនបាយមួយពេលដោយឥតគិតថ្លៃ ដល់កម្មករនិយោជិតដែលស្ម័គ្រចិត្តធ្វើការនៅថ្ងៃអាទិត្យ។

ដោយឡែក ចំពោះការទាមទាររបស់កម្មករនិយោជិតឱ្យក្រុមហ៊ុនផ្តល់ប្រាក់ថ្លៃបាយ ចំនួន ៣០០០ រៀល ដល់កម្មករនិយោជិតដែលស្ម័គ្រចិត្តធ្វើការនៅថ្ងៃអាទិត្យ គឺជាការទាមទារលើសពីច្បាប់កំណត់ឱ្យ ពីព្រោះច្បាប់តំរូវឱ្យតែ ២០០០ រៀល តែប៉ុណ្ណោះ ហេតុនេះ ការទាមទារនេះ ជាវិវាទអំពីផលប្រយោជន៍។

ចំពោះវិវាទទាក់ទងនឹងផលប្រយោជន៍ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចធ្វើការដោះស្រាយបាន លុះត្រាតែសហជីពដែលទាមទារនាំយកវិវាទនោះមក ជាសហជីពដែលមានភាពជាតំណាងនៅក្នុងសហគ្រាស ឬសហជីពច្រើនរួមគ្នាទៅ មានចំនួនសមាជិកលើសពីពាក់កណ្តាលនៃកម្មករនិយោជិតនៅក្នុងសហគ្រាស។ (សូមមើលសេចក្តីបង្គាប់ *លេខ៨១/០៤-អេវើហ្គ្រីន ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី៤ និងលេខ ៩៨/០៤-ហ្គ្រេតយូនៀន ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី៣*)។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាពជាតំណាងបំផុតរបស់សហជីពនេះ ផ្តល់សមត្ថភាពផ្នែកផ្លូវច្បាប់ក្នុងការចរចាបង្កើតអនុសញ្ញារួមក្នុងក្រុមហ៊ុនមួយ និងសិទ្ធិស្របច្បាប់ក្នុងការនាំសំណុំរឿងវិវាទណាមួយ មកឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការដោះស្រាយ។ (សូមមើលសេចក្តីបង្គាប់ *លេខ ៥៧/០៦-អេវើគ្រីន. លេខ ៨១/០៤-អេវើហ្គ្រីន និងលេខ ៩៨/០៤-ហ្គ្រេត យូនៀន*)។

ដើម្បីទទួលបានភាពជាតំណាងបំផុតនេះ មាត្រា ២៧៧ នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ចែងថា សហជីពត្រូវចុះបញ្ជិកា និងត្រូវបំពេញតាមលក្ខខណ្ឌផ្សេងៗទៀត ដែលមានចែងក្នុងមាត្រានេះ។

ក្នុងសំណុំរឿងវិវាទនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានរកឃើញថា សហជីពយុវជនខ្មែរប្រចាំរោងចក្រ មិនទាន់មានវិញ្ញាបនបត្របញ្ជាក់ពីភាពជាតំណាងបំផុតក្នុងរោងចក្រទេ។

THE ARBITRATION COUNCIL

នៅក្នុងសេចក្ដីបង្គាប់អាជ្ញាកណ្ដាលលេខ ០៧/០៦-ដាយ៉ាំង ហេតុផលនៃសេចក្ដីសម្រេចចំណុចវិវាទទី៣ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានពន្យល់ថា " *សិទ្ធិនេះជារបស់សហជីព ដែលបានចុះបញ្ជិកា ដែលមានសមាជិកច្រើនជាងគេ ហើយបំពេញបានតាមលក្ខណៈវិនិច្ឆ័យឯទៀត ដែលមានចែងក្នុងមាត្រា ២៧៧ នៃច្បាប់ស្ដីពីការងារ* "។

ដូច្នេះ ដើម្បីឱ្យមានភាពស្របគ្នានឹងសំណុំរឿងមុនៗនោះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា សហជីពយុវជនខ្មែរនេះ មិនទាន់មានលក្ខណៈគ្រប់គ្រាន់តាមផ្លូវច្បាប់ ក្នុងការធ្វើជាតំណាងឱ្យកម្មករនិយោជិត ដើម្បីដោះស្រាយវិវាទដែលទាក់ទងទៅនឹងផលប្រយោជន៍រួមរបស់កម្មករនិយោជិតទាំងអស់ នៅក្នុងក្រុមហ៊ុននៅឡើយទេ។

ម្យ៉ាងវិញទៀត មាត្រា ៤៣ នៃប្រកាសលេខ ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា "*សេចក្ដីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ដែលដោះស្រាយវិវាទពាក់ព័ន្ធនឹងផលប្រយោជន៍ នឹងមកជំនួសអនុសញ្ញារួមសំរាប់រយៈពេលមួយឆ្នាំ ចាប់ពីថ្ងៃដែលសេចក្ដីបង្គាប់នោះចូលជាស្ថាពរ លើកលែងតែភាគីចរចាបង្កើតអនុសញ្ញារួមមួយ ដើម្បីជំនួសសេចក្ដីបង្គាប់នេះ*" ។

កន្លងមកក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ប្រសិនបើក្រុមប្រឹក្សាអាជ្ញាកណ្ដាលចេញសេចក្ដីបង្គាប់លើចំណុចនេះ វានឹងក្លាយជាអនុសញ្ញារួមដែលអនុវត្តទៅលើកម្មករទាំងអស់ក្នុងក្រុមហ៊ុន ហើយធ្វើឱ្យកម្មករនិយោជិតដទៃទៀត ដែលមិនមែនជាសមាជិកសហជីពនេះ បាត់បង់សិទ្ធិក្នុងការធ្វើកូដកម្ម ដើម្បីទាមទារលើវិវាទដែលទាក់ទងនឹងផលប្រយោជន៍នាពេលអនាគត។ ហេតុដូច្នេះហើយ វានឹងបង្កើតឱ្យមានភាពមិនត្រឹមត្រូវយុត្តិធម៌សំរាប់កម្មករនិយោជិតទាំងនោះ។ (សូមមើលសេចក្ដីបង្គាប់អាជ្ញាកណ្ដាល*លេខ ៥៧/០៤-អេវើហ្គ្រីន, លេខ ៦០/០៤-យូណាយធីតអាត ហេតុផលនៃសេចក្ដីសម្រេច ចំណុចវិវាទទី៣ និងលេខ ០៨/០៧-ស៊ាវ គិញ ហេតុផលនៃសេចក្ដីសម្រេច ចំណុចវិវាទទី៣*) ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេច បដិសេធពិចារណាការទាមទាររបស់កម្មករនិយោជិត ឱ្យក្រុមហ៊ុនផ្ដល់ប្រាក់ថ្លៃបាយ ចំនួន ៣០០០ រៀល ដល់កម្មករនិយោជិតដែលស្ម័គ្រចិត្តធ្វើការនៅថ្ងៃអាទិត្យ ។

យោងតាមអង្គហេតុ អង្គច្បាប់ និងហេតុផលដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេចចេញសេចក្ដីបង្គាប់ដូចតទៅ :

## សម្រេច និង បង្គាប់

### ១. សេចក្ដីបង្គាប់ទាក់ទងនឹងវិវាទអំពីសិទ្ធិ:

**ចំណុចវិវាទទី១១ :** បង្គាប់ឱ្យនិយោជកផ្ដល់ប្រាក់ថ្លៃបាយចំនួន ២០០០ (ពីរពាន់) រៀល ក្នុងមួយថ្ងៃ ឬផ្ដល់ជូនបាយមួយពេលដោយឥតគិតថ្លៃ ដល់កម្មករនិយោជិតដែលស្ម័គ្រចិត្តធ្វើការនៅថ្ងៃអាទិត្យ ។

**ប្រភេទនៃសេចក្ដីបង្គាប់ទាក់ទងនឹងវិវាទអំពីសិទ្ធិ:**

*សេចក្ដីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅក្នុងសេចក្ដីសម្រេចផ្នែកទី១នេះ នឹងក្លាយជាស្ថាពរភ្លាម ហើយអនុវត្តចំពោះភាគីតែម្ដង ដោយយោងតាមអនុស្សរណៈនៃការយោគយល់គ្នា ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ ២០១០។*

## ២. សេចក្ដីបង្គាប់ទាក់ទងនឹងវិវាទអំពីផលប្រយោជន៍:

**ចំណុចវិវាទទី១១** : បដិសេធពិចារណាការទាមទាររបស់កម្មករនិយោជិតឱ្យក្រុមហ៊ុនផ្ដល់ប្រាក់ថ្លៃបាយចំនួន ៣០០០ រៀល ដល់កម្មករនិយោជិតដែលស្មគ្រ័ចិត្តធ្វើការនៅថ្ងៃអាទិត្យ។

**ប្រភេទនៃសេចក្ដីបង្គាប់ទាក់ទងនឹងវិវាទអំពីផលប្រយោជន៍:**

*សេចក្ដីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅក្នុងសេចក្ដីសម្រេចផ្នែកទី២នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្ដីបង្គាប់ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាលក្នុងរយៈពេលនេះទេ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល**

**អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក :**

ឈ្មោះ : **យូ សួនធី**

ហត្ថលេខា: ------------------------------

**អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត :**

ឈ្មោះ : **លឹម សុវណ្ណា**

ហត្ថលេខា: ------------------------------

**ប្រធានក្រុមអាជ្ញាកណ្ដាល :**

ឈ្មោះ : **ម៉ែន ម៉ុនឈា**

ហត្ថលេខា: ------------------------------